# បដិមាព្រះឥសូរមកពីប្រាសាទភ្នំក្រោម

ប្រាសាទភ្នំក្រោម មានទីតាំងស្ថិតនៅភូមិភ្នំក្រោម សង្កាត់សៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប ស្ថិតនៅជិតបឹងទន្លេសាប មានចម្ងាយប្រមាណ១៦គីឡូម៉ែត្រ ប៉ែកនិរតីទីក្រុងអង្គរ ដែលកសាងនៅលើកំពូលភ្នំធម្មជាតិមួយមានកម្ពស់១៣៧ម៉ែត្រ និងធ្លាប់ទទួលបានការអភិរក្សដោយលោក Maurice Glaize កាលពីឆ្នាំ១៩៣៨ ដូចប្រាសាទភ្នំបូកដែរ។ ប្រាសាទនេះមានប្រាង្គសំខាន់ចំនួន ៣ ដែលប្រាង្គនីមួយៗសុទ្ធសឹងមានតម្កល់ទេពសំខាន់ៗនៃព្រហ្មញ្ញសាសនា ដែលគេច្រើនស្គាល់ថា "ត្រីមូតិ" ពោល គឺប្រាង្គកណ្តាលតម្កល់បដិមាព្រះឥសូរ ប្រាង្គខាងត្បូងតម្កល់បដិមាព្រះព្រហ្ម និងប្រាង្គខាងជើងតម្កល់បដិមាព្រះវិស្ណុ។ តើបដិមាព្រះឥសូរដែលរកឃើញនៅប្រាសាទភ្នំក្រោម មានប្រវត្តិ និងលក្ខណៈដូចម្តេចខ្លះ?

ព្រះឥសូរ គឺជាអាទិទេពមានឫទ្ធិអំណាចធំលើសគេក្នុងចំណោមទេពទាំងបី (ត្រីមូតិ) មានតួនាទីជាអ្នកបំផ្លាញលោក ដើម្បីបង្កើតលោកថ្មីឡើងវិញ។ ទ្រង់មានយានជំនិះជាគោនន្ទិ និងមានព្រះមហេសីព្រះនាមឧមា និងបរ្វតី។ នៅសម័យមុនអង្គរ បដិមាព្រះឥសូរក្នុងទម្រង់ជាមនុស្សមិនមាននិយមនោះទេ ពោល គឺច្រើនប្រតិស្ឋានជាសិវលិង្គ រីឯទម្រង់ជាមនុស្សមានតែចម្លាក់តិចតួចប៉ុណ្ណោះ។ ដោយឡែក មកដល់ស.វ.ទី៩ ការប្រតិស្ឋានព្រះឥសូរក្នុងទម្រង់ជាមនុស្សចាប់ផ្តើមមានភាពលេចធ្លោខ្លាំង ជាពិសេស ក្នុងរជ្ជកាលព្រះបាទស្រីឥន្ទ្រវរ្ម័នទី១ (គ.ស.៨៧៧ - ៨៨៩) និងព្រះបាទស្រីយសោវរ្ម័នទី១ (គ.ស.៨៨៩ - ៩១០)។ ដូច្នេះហើយ បដិមាព្រះឥសូរដែលរកឃើញនៅភ្នំក្រោម ក្នុងរជ្ជកាលព្រះបាទស្រីយសោវរ្ម័នទី១ ដែលយើងលោកមកសិក្សានេះ គឺជាឧទាហរណ៍មួយនៃការវិវឌ្ឍសិល្បៈ និងជំនឿព្រហ្មញ្ញសាសនារបស់ខ្មែរនាសម័យបុរាណ។

បដិមាព្រះឥសូរនៅប្រាសាទភ្នំក្រោម កំពុងរក្សាទុក និងដាក់តាំងបង្ហាញនៅសារមន្ទីរជាតិកម្ពុជា ដែលមានលេខបញ្ជី ក.2533 មានកម្ពស់សរុប ២១០សង់ទីម៉ែត្រ (គិតទាំងមកុដ និងពន្លួញ) និងទទឹងស្មាមានប្រវែង ៦៥សង់ទីម៉ែត្រ។ យោងតាមរបាយការណ៍របស់សាលាបារាំងចុងបូព៌ាប្រទេស ដែលដឹកនាំដោយលោក Maurice Glaize កាលពីឆ្នាំ១៩៣៨ បានរៀបរាប់ថា មុនមានការអភិរក្ស បដិមាព្រះឥសូរនេះបានបាក់បែកដោយសារកំទេចថ្មបាក់បែកនៅប្រាង្គកណ្តាល ហើយទី

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

តាំងបដិមាក៏បានចល័តចេញពីខាងក្នុងប្រាសាទដូចគ្នា។ ក្នុងឆ្នាំដដែលនេះ លោកបានប្រមូលបំណែកនានាមកផ្គុំជាមួយជើងទម្រដែលកំពុងស្ថិតនៅទីតាំងដើមនៅឡើយ។ មកដល់ឆ្នាំ១៩៥៣ បដិមានេះបានដួលដោយខ្លួនឯង ដោយសារតែការជួសជុលនៅត្រង់កជើងបដិមានៅពេលនោះពុំសូវមានបច្ចេកទេសរឹងមាំ។ ក្រោយមក នៅឆ្នាំ១៩៦៨ ដោយសារតែមានសង្គ្រាមស៊ីវិលក្នុងស្រុក គេបានចល័តបដិមានេះទៅរក្សាទុកនៅអភិរក្សដ្ឋានអង្គរ ហើយក្រោយមកទៀតព្រះសិរបដិមានេះ ត្រូវបានគេរត់ពន្ធលួចចេញពីអភិរក្សដ្ឋានអង្គរទៅដល់ក្រៅប្រទេស។

ក្រោមកិច្ចសហការរវាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ជាមួយ The Metropolitan Museum of Art នៅក្នុងឆ្នាំ១៩៩៧ ព្រះសិរព្រះឥសូរនេះបានប្រគល់ជូនសារមន្ទីរជាតិកម្ពុជាវិញ ដើម្បីយកមកផ្គុំជាមួយដងខ្លួនឱ្យពេញលក្ខណៈ។ ចំណុចនេះ បានក្លាយជារបត់ថ្មីបំផុតមួយនៃការប្រគល់វត្ថុបុរាណពីបរទេសមកកាន់កម្ពុជា ហើយបានក្លាយជាគំរូសម្រាប់សារមន្ទីរដទៃទៀតនៅបរទេសក្នុងការពិនិត្យមើលបញ្ជីវត្ថុបុរាណរបស់ខ្លួនឡើងវិញ រហូតមកទល់បច្ចុប្បន្នមានវត្ថុបុរាណខ្មែរជាច្រើន បានធ្វើមាតុភូមិនិវត្តន៍មកកាន់កម្ពុជាជាបន្តបន្ទាប់។ នៅក្នុងរបាយការណ៍របស់សារមន្ទីរ The MET នាឆ្នាំ១៩៩៧ លោក Philippe de Montebello នាយកសារមន្ទីរ បានប្ដេជ្ញាចិត្តខ្ពស់ក្នុងការដោះស្រាយចំពោះវត្ថុបុរាណដែលមកដល់ដោយមិនមានប្រភពច្បាស់លាស់ ហើយការផ្គុំគ្នារវាងព្រះសិរ និងដងខ្លួននេះ គឺជាភស្តុតាងវិទ្យាសាស្ត្រដែលមិនអាចប្រកែកបាន។ សូមបញ្ជាក់ថា ការទាមទារព្រះសិរបដិមាព្រះឥសូរមកវិញបាននៅពេលនោះ គឺធ្វើឡើងដោយមានការស្រាវជ្រាវផ្ទៃក្នុង និងកិច្ចសហការជាមួយអ្នកជំនាញសាលាបារាំងចុងបូព៌ាប្រទេស ដែលបង្ហាញថា ព្រះសិរនេះ គឺជាផ្នែកដែលបាត់បង់នៃបដិមាព្រះឥសូររកឃើញនៅភ្នំក្រោម និងកំពុងស្ថិតនៅសារមន្ទីរជាតិកម្ពុជា។

លោក Jean Boisselier យល់ថា ព្រះភក្ត្រព្រះឥសូររកឃើញនៅភ្នំក្រោមនេះ មានរាងមូល និងមានលក្ខណៈរឹងមាំជាងបដិមាព្រះឥសូរដែលរកឃើញនៅក្នុងរជ្ជកាលព្រះបាទស្រីឥន្ទ្រវរ្ម័នទី១។ ទ្រង់មានព្រះមស្សុ (ពុកមាត់) ក្រាស់ និងខាងចុងងើរឡើងលើ ព្រះភមូ (ចិញ្ចើម) ភ្ជាប់គ្នាវែង ព្រះនេត្របិទក្នុងរបៀបស្មិងស្មាធិ៍ និងព្រះកាណ៌ (ត្រចៀក) វែង។ ចំណែកព្រះនេត្រទី៣ដែលឆ្លាក់បញ្ឈរនៅលើថ្ងាស លោក Jean Boisselier គិតថា មានទម្រង់ច្បាស់លាស់ជាសញ្ញាសម្គាល់នៃអំណាចក្នុងការបំផ្លាញលោករបស់ព្រះឥសូរយ៉ាងពិតប្រាកដ។ ដោយឡែក ផ្នួងសក់វិញ លោកបានកត់សម្គាល់ថា រចនាឡើងជារាងស៊ីឡាំងខ្ពស់ដែលមានចម្លាក់តូចៗបញ្ឈរជាជួរៗ ក្នុងរទម្រង់

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ជាជដាមកុដ ដោយមានចម្លាក់ចំណិតព្រះចន្ទនៅលើផ្នួងសក់ ដែលបញ្ជាក់ឱ្យឃើញច្បាស់អំពីលក្ខណៈសម្គាល់របស់ព្រះឥសូរ។ ផ្នួងសក់ខ្ពស់ឬវែងបែបនេះ បានបង្ហាញឱ្យឃើញយ៉ាងច្បាស់អំពីការផ្លាស់ប្តូរពីផ្នួងសក់ទាបៗនៅសម័យមុន មកជាទម្រង់ផ្នួងសក់ខ្ពស់ជាងមុនច្រើន ដែលអាចបង្ហាញអំពីភាពរុងរឿងនៃសម័យអង្គរ។

ចំពោះដងខ្លួន លោក Jean Boisselier យល់ថា ដងខ្លួនបដិមាព្រះឥសូរនៅភ្នំក្រោម គឺបង្ហាញឱ្យឃើញភាពសមាមាត្ររវាងដងខ្លួន ជាមួយផ្នែកខាងលើ (ព្រះកគ្រ្គ) និងផ្នែកខាងក្រោម (ជើង) ដោយមានស្មារីកធំទូលាយ ដើមទ្រូងមាំមួន និងមានការបង្ហាញសាច់ដុំនៅត្រង់ពោះយ៉ាងច្បាស់លាស់ ដែលឆ្លុះបញ្ចាំងឱ្យឃើញពីឧត្តមភាពនៃកម្លាំង។ ឥរិយាបថឈរទៀត គឺឈរត្រង់ក្នុងទម្រង់ជា **"សមបាទស្ថានក"** (samapādasthānaka) សំដៅដល់ឥរិយាបថឈរដ៏មានលំនឹងរឹងមាំមួយដែលមានជើងស្មើទៅនឹងខ្សែអ័ក្សកណ្តាលនៃរូប (មធ្យសុត្រ) ក្បាល និងដងខ្លួនដាក់ឱ្យត្រង់ជើង និងដៃនៅជាប់គ្នា ពងកាយគ្មានការបត់បែនទៅទិសណាមួយ ហើយសម្លឹងឆ្ពោះទៅមុខត្រង់ ឆ្លុះបញ្ចាំងឱ្យឃើញពីភាពថ្លៃថ្នូរក្នុងនាមជាអាទិទេពកំពូលនៃព្រហ្មញ្ញសាសនា។

ដោយឡែក បដិមានេះស្លៀកសំពត់ខ្លីដែលមានក្បិតូចល្អិតៗនិងជិតគ្នាបំផុត មានជាយធ្លាក់សំយាកមកគ្របនៅលើភ្លៅខាងឆ្វេង និងមានជាយពងជាយុថ្កាពីរជាន់ទម្លាក់ចុះមកចំពីមុខ ដែលជាយខាងក្រៅវែងជាងជាយខាងក្នុង ព្រមទាំងមានជាយតូចៗពីរទៀតអមសងខាងទម្លាក់មកលើភ្លៅសងខាង។ ចុងរបស់ជាយធ្លាក់សំយ៉ុងពីខាងមុខពងដូចកន្ទុយត្រីត្រួតគ្នា។ លក្ខណៈបែបនេះ គឺជាការវិវឌ្ឍថ្មីដោយឡែកពីសិល្បៈនៅក្នុងរជ្ជកាលព្រះបាទស្រីឥន្ទ្រវរ្ម័នទី១ ដែលត្រូវជាព្រះបិតារបស់ព្រះបាទស្រីយសោវរ្ម័នទី១ ព្រោះទេវរូបភេទប្រុសនៅក្នុងរចនាបថព្រះគោស្លៀកសំពត់ខ្លីមិនមានក្បិ និងជាយធ្លាក់មកពីរជាន់ចំពីមុខដូចបដិមានេះទេ។

ជារួមមក បដិមាព្រះឥសូររកឃើញនៅប្រាសាទភ្នំក្រោម គឺជាភស្តុតាងបង្ហាញឱ្យឃើញពីរបត់នៃការផ្លាស់ប្តូររវាងសិល្បៈរចនាបថព្រះគោ និងសិល្បៈរចនាបថបាខែងជាច្រើនចំណុច ជាពិសេស គឺបង្ហាញឱ្យឃើញការប្រតិស្ឋានបដិមាធំជាងសម័យមុនៗ។ បដិមានេះ គឺជាសក្ខីភាពនៃជំនឿព្រហ្មញ្ញសាសនា ក្នុងលទ្ធិសៃវនិយម ដែលបានអនុវត្តនៅក្នុងសង្គមខ្មែរនាសម័យអង្គរ ក៏ហាក់ដូចជាបង្ហាញឱ្យឃើញអំពីមហិច្ឆតារបស់ព្រះបាទស្រីយសោវរ្ម័នទី១ ក្នុងការប្រែក្លាយរាជធានីយសោធរបុរ ឱ្យក្លាយទៅចក្រវាលនៃស្ថានរបស់អាទិទេព។

អត្ថបទដោយៈ ម៉ង់ វ៉ាលី

# បញ្ជីឯកសារពិគ្រោះ


Baptiste, P. and Zéphir, T. (2008) *L'art khmer: Dans les collections du Musée Guimet*. Paris: Réunion des musées nationaux.

Boisselier, J. (1955) *La statuaire khmère et son évolution*, Paris. pp. 162-165.

Boisselier, J. (1966) *Le Cambodge*. Paris: Picard.

Glaize, M. (1938) 'Chronique: Conservation d'Angkor', *Bulletin de l'École française d'Extrême-Orient (BEFEO)*, 38(2), pp. 441-452.

Glaize, M. (1944) *Les Monuments du groupe d'Angkor*. Saigon: Portail.

Jessup, H.I. (2006) *Art & Architecture of Cambodia*. London: Thames & Hudson.

Le Bonheur, A. (1989) *Cambodge: Angkor, temples en péril*. Paris: Herscher.



*រូបលេខ១៖ បដិមាឥសូរតម្កល់ខាងក្នុងប្រាសាទភ្នំក្រោម នាឆ្នាំ១៩៣៨* (ប្រភព៖ EFEO)





*រូបលេខ២-៣៖ បដិមាព្រះឥសូរនៅខាងមុខប្រាសាទភ្នំក្រោម នាឆ្នាំ១៩៣៨* (ប្រភព៖ EFEO)

*អត្ថបទដោយ៖ ម៉ង់ វ៉ាលី*



រូបលេខ២៨-៥៖ បដិមាព្រះឥសូរមកពីប្រាសាទភ្នំក្រោម តម្កល់នៅសារមន្ទីរជាតិកម្ពុជា

អត្ថបទដោយៈ ម៉ង់ វ៉ាលី





រូបលេខ៦-៧៖ លម្អិតផ្នែកខាងលើនៃបដិមាព្រះឥសូរមកពីប្រាសាទភ្នំក្រោម



រូបលេខ៨៖ លម្អិតសម្លៀកបំពាក់បដិមាព្រះឥសូរមកពីប្រាសាទភ្នំក្រោម

អត្ថបទដោយ៖ ម៉ង់ រ៉ាលី